ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍
រឿងក្តីព្រហ្មទណ្ឌ
លេខៈ៤១៥
ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០
សាលដីកា
លេខៈ៨៣ ក្រV បស
ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២

សាលាឧទ្ធរណ៍បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២០-០៦-២០១២ដែលមានសមាសភាពដូចខាងក្រោម៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

១-លោក .... ជាប្រធាន

២-លោក .... ចៅក្រមប្រឹក្សា

៣-លោក .... ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក .... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-លោក ................

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ៤១៥ ចុះថ្ងៃទី១៤-៦-២០១២ របស់សាលាឧទ្ធរណ៍ដែលមាន៖

១-ជនជាប់ចោទឈ្មោះ...ភេទប្រុស អាយុ២៦ ឆ្នាំជាតិខ្មែរ មានមុខរបររកស៊ីលក់ដូរ កើតនៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានទីលំនៅសព្វថ្ងៃនៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានឪពុកឈ្មោះ....ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ......មានកូន០១នាក់ ទោសពីមុនគ្មាន។

២-ជនជាប់ចោទឈ្មោះ....ភេទប្រុស អាយុ៤៤ ឆ្នាំ ជាតិខ្មែរឥស្លាម កើតនៅភូមិត្រពាំងខ្លុង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ចាម មានមុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិចុងខ្លុយ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ.....ម្តាយឈ្មោះ......ប្រពន្ធឈ្មោះ.........មានកូន០៧នាក់ ទោសពីមុនគ្មាន។

-ជនជាប់ចោទទាំងពីរមានលោក...ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

ជាប់ចោទពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្ត នៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ជនជាប់ចោទទាំងពីរ អមដោយលោក.........មេធាវីការពារសិទ្ធិជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ.......ភេទស្រីអាយុ៥០ឆ្នាំ នៅភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ដោយមានលោក...... និងលោកមេធាវីតំណាងដោយអាណត្តិ ឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

## ឯរឿងហេតុមានដូចតទៅ

សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ........ភេទប្រុសបានធ្វើដំណើរមកពីលេងផ្ទះកូនទៅភូមិចុងខ្លងឃុំអូរសណ្តាន់ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ៥ ឆ្ពោះមកទីរួមខេត្តពោធិ៍សាត់។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ នៅវេលាម៉ោង១១ និង៣០នាទី មានជនល្មើសចំនួន០២នាក់ ជិះម៉ូតូឌុបគ្នាមកតាមក្រោយ មកដល់កៀក បានបាញ់ជនរងគ្រោះនឹងកាំភ្លើងខ្លីចំនួនមួយគ្រាប់ត្រូវក្រោមឆ្អឹងជំនីរខាងឆ្វេងបណ្តាលឱ្យរបួសធ្ងន់ និងបណ្តាលឱ្យស្លាប់ក្រោយពីបានសង្គ្រោះនៅមន្ទីរពេទ្យ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៤ (ជ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ឱ្យឈ្មោះ...........រួចខ្លួនពីបទចោទពីបទ មនុស្សឃាតគិតទុកជាមុនប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-លើកចោលការប្តឹងទាមទារជំងឺចិត្ត របស់អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ...........ចំនួន ១0000(ដប់ពាន់ដុល្លាអាមេរិក) ពីជនជាប់ចោទឈ្មោះ.......ដោយខុសទៅនឹងគតិច្បាប់។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាស

ជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្ដឹងរដ្ឋប្បវេណី។

បើកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ...តំណាងអយ្យការ សុំប្ដឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ០៤ (ជ) ចុះថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុច ទាំងមូលនៃសាលក្រម។

-បានឃើញរបាយការណ៍សំណុំរឿងព្រហ្មទណ្ឌលេខ៤១៥ ចុះថ្ងៃទី១៤-០៦-២០១០ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

-បានឃើញសេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

-បានឃើញសាលដីការបៀបលេខ០៣ ក្រVបស ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាអានសាលដីការបៀបលេខ០៣ ក្រVបស ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១

-ជនជាប់ចោទឈ្មោះ...........(អវត្តមាន)

-ជនជាប់ចោទឈ្មោះ...........(អវត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក......(វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ...........(អវត្តមាន)

-មេធាវីការពារឈ្មោះ............(វត្តមាន)

-មេធាវីការពារឈ្មោះ............(វត្តមាន)

-កូនរបស់ជនរងគ្រោះឈ្មោះ.......(វត្តមាន)

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ..........

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ..........

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ..........

-ឈ្មោះ.......ជាកូនរបស់ជនរងគ្រោះបានឆ្លើយថា មុនពេលឪពុកស្លាប់ទៅគាត់ប្រាប់ថាឈ្មោះ....ជាអ្នកដេញបាញ់គាត់។ ជនជាតិចាម គឺគេប្រើឈ្មោះប្រពន្ធជាគោល ព្រោះប្តីមានត្រកូលដូចៗគ្នា ទើបគេប្រើឈ្មោះប្រពន្ធមុនប្តីដាក់ឈ្មោះហៅក្រោយ នេះជាទម្លាប់របស់ជនជាតិ។រូបភាពនិងស៊ីឌីថតសម្លេងបានបញ្ចូលជាភស្តុតាងរួចហើយ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

-មេធាវីលោក.......បានធ្វើសេចក្តីសន្និដ្ឋាន ពេលវេលាដែលបានបញ្ជាក់ទាំងសាក្សីនិងពេលវេលាដែលជនរងគ្រោះ បញ្ជាក់គឺពេលវេលាត្រូវគ្នាជាក់លាក់ស៊ីសង្វាក់គ្នា ដែលជនរងគ្រោះលើកឡើងមុនស្លាប់ព្រោះកើតហេតុនៅចន្លោះម៉ោង១០ ថ្ងៃ ទៅម៉ោង១១ និង៤៥ នាទី សូមក្រុមប្រឹក្សាពិចារណា។

-មេធាវីលោក......បានធ្វើសេចក្តីសន្និដ្ឋាន រឿងក្តីនេះកើតឡើងដោយមានគំនុំលើកកូនក្តីខ្ញុំ សម្តីចុងក្រោយរបស់ជនរងគ្រោះ បានឆ្លើយរួចហើយមុននឹងស្លាប់គាត់ឆ្លើយថាឈ្មោះ.....ជាអ្នកសម្លាប់គាត់ ។សូមផ្តល់យុត្តិធម៌ដល់កូនក្តីខ្ញុំ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-អង្គហេតុជនរងគ្រោះ បានឆ្លើយបញ្ជាក់ថា ឈ្មោះ....និងឈ្មោះ......ដោយបញ្ជាក់ទាំងឈ្មោះប្រពន្ធជនជាប់ចោទ ទៀតផង ពេលវេលាកាលៈទេសៈ

ប្រព្រឹត្តម៉ោង១១ថ្ងៃ ជនរងគ្រោះស្លាប់គ្មានច្បាស់ ហេតុនេះគួរបដិសេធសាលក្រម សាលាដំបូងសុំចោទប្រកាន់ ដូចដែលអយ្យការសាលាដំបូងបានចោទប្រកាន់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-មេធាវីការពារលោក..........ឆ្លើយការពារថាៈថ្ងៃកើតហេតុនៅចន្លោះ ម៉ោង១១ ស៊ីសង្វាក់ជាមួយសាក្សី ប៉ុន្តែពេលវេលារបស់ជនជាប់ចោទវាខុសគ្នា ទៅនឹងពេលវេលារបស់ជនរងគ្រោះដែលបានឆ្លើយ ភស្តុតាងជាគ្រាប់កាំភ្លើង សំបកគ្រាប់ ស្នាមរបួសដែលបាញ់ត្រូវ ក៏ពុំឆ្លើយជាក់លាក់នោះទេ សូមតម្កល់ សាលក្រមព្រហ្មទណ្ឌសាលាដំបូងខេត្តពោធិ៍សាត់។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់អំណានសាលដីការបៀប

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់ចម្លើយរបស់កូនជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យដើមបណ្តឹង

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ខែមីនាឆ្នាំ២០១០របស់ឈ្មោះ...ជាតំណា ងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាម មាត្រា៣៨១នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជម្រះ។

២-កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ........ភេទប្រុសបានធ្វើដំណើរមកពីលេងផ្ទះកូននៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ៥ ឆ្ពោះមកទីរួមខេត្តពោធិ៍សាត់ ។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ នៅវេលាម៉ោង១១ និង៣០នាទី មានជនល្មើសចំនួន០២នាក់ ជិះម៉ូតូឌុបគ្នាមកតាមក្រោយ មកដល់កៀកបានបាញ់ជនរងគ្រោះនឹងកាំភ្លើងខ្លីចំនួនមួយគ្រាប់ ត្រូវក្រោមឆ្អឹងជំនីរខាងឆ្វេងបណ្តាលឱ្យរបួសធ្ងន់ ហើយបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ។ រយៈពេលសម្រាកព្យាបាល នៅមន្ទីរពេទ្យជនរងគ្រោះបាននិយាយប្រាប់ថាអ្នកបាញ់ខ្លួនគឺគាត់ស្គាល់មានឈ្មោះ.......ប្រពន្ធឈ្មោះ........ និងម្នាក់ទៀត ឈ្មោះ........ប្រពន្ធឈ្មោះ.......នៅថ្ងៃទី១៣-៦-២០០៩ជនរងគ្រោះបានស្លាប់នៅមន្ទីរពេទ្យខេត្តបាត់ដំបង។

៣-តាមការស៊ើបអង្កេតស្រាវជ្រាវរបស់សមត្ថកិច្ច ជនជាប់ចោទមានឈ្មោះ.....ប្រពន្ធឈ្មោះ.....មានឈ្មោះ.....ភេទ ប្រុសអាយុ២៦ឆ្នាំ ជនជាតិឥស្លាម និងជនជាប់ចោទឈ្មោះ...ប្រពន្ធឈ្មោះ.........គឺមានឈ្មោះ......ភេទប្រុសអាយុ៤៤ឆ្នាំ ជនជាតិឥស្លាម អ្នកទាំងពីររស់នៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។

៤-តាមការអះអាងរបស់ជនជាប់ចោទ ឈ្មោះ..នាពេលសវនាការសាលាដំបូងថា នៅថ្ងៃទី១៦-៦-២០០៩ ខ្លួនបាន បើកឡានជូនប្រពន្ធទៅលក់ចានឆ្នាំង តាំងពីព្រលឹមពេលជូនរួចហើយ ត្រឡប់មកវិញ ។ នៅថ្ងៃនោះចន្លោះម៉ោង១០ព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់ខ្លួនមិនបានចេញទៅណាទេ គឺនៅបោកខោអាវ ងូតទឹកហូបបាយផ្ទះ បន្ទាប់មកចូលថ្វាយបង្គំ ព្រះដែលនៅក្បែរ

ផ្ទះ។ នៅម៉ោង១២ជាង នគរបាលបានមកហៅទៅសាកសួរនៅប៉ុស្តិ៍នគរបាលអូរសណ្តាន់។

៥-តាមការអះអាងរបស់ជនជាប់ចោទ ឈ្មោះ....នាពេលសវនាការសាលាដំបូងថា នៅថ្ងៃទី១១-៦-២០០៩ ចន្លោះ ម៉ោង១១ ទៅ១២ ថ្ងៃត្រង់ខ្លួនផឹកកាហ្វេក្នុងតៀមកាហ្វេក្បែរសាលាឃុំអូរសណ្តាន់ មានសាក្សីច្រើននាក់ដែលផឹកកាហ្វេជាមួយគ្នាពិសេសឈ្មោះ....ជានាយនគរបាលប៉ុស្តិ៍ ក៏ផឹកកាហ្វេទីនោះដែរ ហើយមានចម្ងាយពីទីតាំងកើតហេតុ។

៦-តាមសាលដីកាព្រហ្មទណ្ឌរបៀបលេខ០៣ក្រVបសចុះថ្ងៃទី២៧-៧-២០១១ របស់សាលាឧទ្ធរណ៍ ដែលបានចាត់ឱ្យស៊ើបសួរបន្ថែម នោះតុលាការបានធ្វើការស៊ើបសួរបន្ថែមឃើញថា៖

ក/តាមចម្លើយរបស់ឈ្មោះ......យកផ្នែកពិនិត្យវិភាគ នៃអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ បានបញ្ជាក់ថានៅថ្ងៃ ទី១១-៦-២០០៩ ខ្លួនមិនបានមើលម៉ោងទេ ពេលចេញពីអធិការដ្ឋានទៅមើលកន្លែងកើតហេតុ តាមបញ្ជាលោកអធិការក្រុងពោធិ៍សាត់ ទៅកន្លែងកើតហេតុប្រហែល៧ និង១០នាទី។ ពេលដល់កន្លែងកើតហេតុឃើញមានប្រជាជនអ៊ូអរ ហើយខ្ញុំដើរពិនិត្យកន្លែងកើតហេតុបន្តិច ទើបចាប់ផ្តើមធ្វើកំណត់ហេតុ ដោយមើលម៉ោងក្នុងទូរស័ព្ទឃើញថាម៉ោង១១ និង១០នាទី។ តាមការបញ្ជាក់របស់ឈ្មោះ......ថាពេលកើតហេតុប្រព្រឹត្តឡើងនៅមុនម៉ោង១១ព្រឹក។

ខ-តាមចម្លើយរបស់ឈ្មោះ.....ជាមេប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃឈើ ថានៅថ្ងៃទី១១-៦-២០០៩ ម៉ោង១១ និង៣០នាទីខ្លួនបានទទួលដំណឹងពីមេភូមិសាលាគំរូឈ្មោះ..តាមរយៈទូរស័ព្ទថា មានករណីបាញ់សម្លាប់លើផ្លូវជាតិលេខ៥ ពេលវេលា ដែលបញ្ជាក់ក្នុងកំណត់ហេតុជាពេលវេលា ដែលបានទទួលដំណឹង

មិនពិតមែនជាពេលវេលា ដែលឃាតករបាញ់លើជនរងគ្រោះទេ។រយៈពេលធ្វើដំណើរបើកម៉ូតូលឿនពីឃុំព្រៃញី ទៅកន្លែងកើតហេតុប្រហែលរយៈពេល១៥នាទីទៅ២០ នាទី។

គ. តបតាមចម្លើយរបស់ឈ្មោះ.....បានបញ្ជាក់ថា ខ្លួនមិនចាំថ្ងៃខែឆ្នាំទេ ពេលព្រឹកម៉ោងប្រហែល១០ និង៣០នាទី ខ្លួន ចេញពីធ្វើការ ហើយទៅផឹកកាហ្វេ នៅភូមិអូរអាចម៍កុក ម៉ោងប្រហែល១១ និង៣០នាទី ក្រោយមកប្រហែល៥នាទីឈ្មោះ ជាជំទប់ទី១ មកដល់ផឹកកាហ្វេជាមួយឈ្មោះ....ក៏មកដល់តំណាលគ្នាដែរ ហើយអង្គុយផឹកកាហ្វេនិយាយគ្នាលេងដោយ ឈ្មោះ...សួរឈ្មោះ...ពីណាឈ្មោះ...ឆ្លើយថាមករកមើលទិញគោរបស់ឈ្មោះ..ការផឹកកាហ្វេរយៈពេលប្រហែល២០នាទី ទើបបែកគ្នា។ ម៉ោងប្រហែល១២និង៣០នាទី បានទទួលបញ្ជាពីអធិការឱ្យរកឈ្មោះ....ខ្លួនក៏បានទៅជួបឈ្មោះ.......នៅ ផ្ទះ ហើយទទួលបញ្ជាឱ្យចាប់ឈ្មោះ.....មិនហានចាប់ព្រោះទៅតែម្នាក់ឯង ហើយប្រាប់ឈ្មោះ.....ភ្លីនៅប៉ុស្តិ៍រដ្ឋបាលអូរសណ្តាន់។

៧-តាមការអះអាងរបស់ប្រជាជន ដែលបានផ្តិតមេដៃលើលិខិតគាំទ្រ (ឯកសារលេខ២០/២១) បានបញ្ជាក់ថាៈ នៅថ្ងៃទី១១-៦-២០០៩ ម៉ោងប្រហែល១១ រហូតដល់ម៉ោង១២ជាង ឈ្មោះ...នៅផ្ទះពុំបានចេញទៅណាទេ ដែលអះអាង នេះផ្ទុយពីឈ្មោះ.....អះអាងថាម៉ោងប្រហែល១១ និង៣០នាទី ឈ្មោះ......នៅផឹកកាហ្វេជាមួយខ្លួនហើយឈ្មោះ.....បាន បញ្ជាក់ថាចាប់ពីម៉ោង១១ព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់ខ្លួនបានចេញទៅផឹកកាហ្វេជាមួយឈ្មោះ..។

៨-តាមញត្តិគាំទ្ររបស់ប្រជាជន(ឯកសារលេខ២១) បានបញ្ជាក់ថា ម៉ោង៩ម៉ោងព្រឹករហូតដល់ម៉ោង១២ និង១៥នាទីឈ្មោះ....នៅក្នុងភូមិរហូតដល់ម៉ោង១២និង១៥នាទីទើបចុះពីព្រះវិហារ ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ.....

(ឯកសារលេខ៣៣) បញ្ជាក់ថាមុនពេលខ្លួនផឹកកាហ្វេនៅភូមិអូរអាចម៍កុកខ្លួនយកឪសទៅធ្វើនៅភូមិពុទ្រាម ដូច្នេះអាចបញ្ជាក់ ឱ្យឃើញថាឈ្មោះ......មិននៅក្នុងភូមិជាប់រហូតដូចការអះអាងក្នុងញត្តិគាំទ្រ(ឯកសារលេខ២១)នោះឡើយ។

៩-ផ្អែកតាមចម្លើយសាក្សី ភស្តុតាង ដែលប្រមូលបានព្រមទាំងចម្លើយជនរងគ្រោះ មុនពេលស្លាប់អាចបញ្ជាក់ឱ្យ ឃើញថាអំពើឃាតកម្មនោះកើតឡើងមុនម៉ោង១១ព្រឹក ហើយការអះអាងរបស់ជនជាប់ចោទឈ្មោះ..........បានផឹកកាហ្វេ ជាមួយឈ្មោះ........ចាប់ពីម៉ោង១១ និង៣០នាទីទៅ បើគិតពីរយៈពេលធ្វើដំណើរពីកន្លែង ទៅកន្លែងកើតហេតុ ជនជាប់ចោទអាចប្រើរយៈពេលតែ១៥នាទីទៅ២០នាទី ប៉ុណ្ណោះ អាចគេចចេញមកដល់ក្នុងភូមិវិញបាន។ ជនរងគ្រោះស្គាល់ច្បាស់អ្នកដែលបាញ់ខ្លួនគឺជាជនជាប់ចោទឈ្មោះ...នេះបញ្ជាក់ឱ្យឃើញថាជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស ហើយក៏ជិះម៉ូតូមកភូមិវិញ ហើយបែកគ្នាដើម្បីបំភាន់សមត្ថកិច្ចមិនឱ្យចាប់អារម្មណ៍ដល់ខ្លួន ម្យ៉ាងទៀតជនជាប់ចោទមិននឹកស្មានថាជនរងគ្រោះនៅមានដង្ហើមអាចនិយាយបាន ទើបបានជាមិនរត់គេចខ្លួន។

១០-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ......ភេទប្រុសអាយុ២៦ឆ្នាំ និងជនជាប់ចោទឈ្មោះ......ភេទ ប្រុសអាយុ៤១ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុនប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១-៦-២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-សេចក្តីសម្រេចនៃសាលក្រមលេខ០៤(ជ) ចុះថ្ងៃទី០៩-២-២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ មានលក្ខណៈ មិនត្រឹមត្រូវតាមច្បាប់ឡើយ គប្បីបដិសេធចោល។

-មេធាវីការពារជនជាប់ចោទ បានបញ្ជាក់ថាជនជាប់ចោទទាំងពីរបាន ទទួលដំណឹងពីកាលបរិច្ឆេទនៃសវនាការរួចហើយ តែអវត្តមានដូចនេះសាល ដីកានេះត្រូវប្រកាសថា កំបាំងមុខជនជាប់ចោទ ចាត់ទុកជាចំពោះមុខ តាម មាត្រា៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ .......ជាតំណាងអយ្យការអមសាលាដំបូង ខេត្តពោធិ៍សាត់ ទុកជាត្រឹមត្រូវតាម ទម្រង់និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ០៤ (ជ) ចុះថ្ងៃទី០៩-០២-២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ចោល។

៣-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ.....ភេទប្រុសអាយុ២៦ឆ្នាំ និងជន ជាប់ចោទឈ្មោះ.....ភេទប្រុសអាយុ៤៤ ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់១៧ ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុង ពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១-៦-២០០៩ តាមមាត្រា៣ នៃច្បាប់ ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៣៥០ ចំណុច១,២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ.................សងសំណងជំងឺចិត្ត ចំនួន ២០,០០០,០០០រៀល(ម្ភៃលានរៀល)ទៅដើមបណ្ដឹងឈ្មោះ....ការទាមទារលើ សពីនេះបដិសេធចោល។

-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ...អនុវត្តទោស នៅពន្ធនាគារ ខេត្តពោធិ៍សាត់ តាមអំណាចសាលដីកានេះ។ តាមមាត្រា៤០៧ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

៥-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី២០-៦-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧-៧-២០១២ ដោយសម្រេចសេចក្តី៖

-កំបាំងមុខជនជាប់ចោទឈ្មោះ.......ចំពោះមុខមេធាវីការពារ ចាត់ទុកចំពោះមុខ

-កំបាំងមុខដើមបណ្តឹងចំពោះមុខមេធាវី

-បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ..ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិព្រៃទទឹង ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

តាមសេចក្ដីសុំប្ដឹងទាស់លេខៈ ៧២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ...ប្ដឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខៈ៣៨ (ញ) ចុះថ្ងៃទី ១៣ ខែ ៨ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល។

**ឯរឿងហេតុមានដូចតទៅៈ**

កាលពីថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោង ១១យប់ ជនល្មើសឈ្មោះ...ភេទប្រុស ដែលមានទីលំនៅ ភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង និងបក្សពួក បាននាំគ្នាពួនស្ទាក់ចាំកាក់ម៉ូតូរបស់ជនរងគ្រោះ ពេលឃើញម៉ូតូរបស់ជនរងគ្រោះជិះកាត់បែរតាមផ្លូវរត់ភ្លើងមកខាងត្បូងបានចម្ងាយប្រហែលជាង ១០០ម ជនល្មើសរូបនេះបានចេញមកកាត់ពីមុខម៉ូតូហើយបញ្ឆោឱ្យឈប់ បន្ទាប់មកទៀតបក្សពួករបស់ជនល្មើសបានលូកហោប៉ៅ របស់ជនរងគ្រោះ យកប្រាក់អស់ចំនួន ១០.០០០រៀល ចំណែកជនរងគ្រោះរត់ចេញពីម៉ូតូចម្ងាយប្រហែលប្រាំម៉ែត្រ តែត្រូវជនល្មើស ស្ទាក់ជាប់ហើយទាមទារយកទូស័ព្ទដៃ ដោយជនរងគ្រោះមិនព្រមឱ្យជនល្មើសក៏កាប់និងចាក់ទៅលើជនរងគ្រោះ បណ្ដាលឱ្យស្លាប់នៅនឹងកន្លែងតែម្ដង បន្ទាប់ពីធ្វើសកម្មភាពទៅលើជនរងគ្រោះហើយ ជនល្មើសក៏នាំគ្នារត់គេចខ្លួនអស់ទៅ។

- តាមកំណត់ហេតុបណ្ដឹងចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ឈ្មោះ...ប្ដឹងពីមនុស្សឃាតដោយចេតនា ដោយអាងហេតុថា កាលពីថ្ងៃទី ០៧. កុម្ភៈ ឆ្នាំ២០០៨ ម៉ោង០១និង០០នាទី ខ្លួនបានទទួលដំណឹងពីឈ្មោះ... ភេទប្រុស ប្រាប់ថា ឈ្មោះ...ត្រូវរបួសធ្ងន់ប្រហែលស្លាប់ហើយ និងឈ្មោះ... ភេទ

ប្រុស អាយុ២៧ឆ្នាំ ត្រូវរបួសនៅចំណុចស្ថានីយ៍រថភ្លើងខេត្តបាត់ដំបង។ពេល នោះខ្លួនមកដល់កន្លែងកើតហេតុនៅវេលាម៉ោង២និង៣០នាទី ឃើញឈ្មោះ... ស្លាប់នៅខាងជើងផ្លូវរថភ្លើង ហើយបាត់ទូរស័ព្ទដៃម៉ាកសាំសុងលេខៈ០១២ ១៩៦១០៥ និងប្រាក់មួយចំនួន។ សំណូមពរសុំឱ្យសមត្ថកិច្ចជួយស្រាវជ្រាវរក សម្ភារឱ្យខ្លួនវិញ ចំណែកជនល្មើសសុំឱ្យសមត្ថកិច្ចផ្ដន្ទាទោសទៅតាមច្បាប់។

-បានឃើញចម្លើយរបស់ឈ្មោះ...ជាជនជាប់ចោទឆ្លើយក្នុងសាលក្រមថា ខ្លួនមិនបានសម្លាប់គេទេ ហើយមិនបានដឹងថា គេស្លាប់ដែរ លុះព្រឹកឡើងទើប ដឹង នៅថ្ងៃនោះម៉ោង ៤ ខ្លួននៅផ្ទះ លុះម៉ោង ៥ ខ្លួនបានទៅលេខបាល់រួចមុជ ទឹក ហើយទៅមើលគេលេងបៀរ ឈ្មោះ...បានមកលេងផ្ទះខ្លួន ហើយខ្លួនក៏ បបួលវាទៅបត់ជើង រួចទៅដើរលេងឈរក្រោមដើមទឹកដោះគោម៉ោង ១០ ជាងទើបមកវិញ ខ្លួនមិនបានដឹងថា ឈ្មោះ...ស្លាប់ នៅពេលណាទេ លុះព្រឹក ឡើងទើបដឹង មិនដឹងអ្នកណាសម្លាប់គេទេ តែនៅយប់នោះវេលាម៉ោង១២ ឈ្មោះ...រកខ្លួនរួចប្រាប់ខ្លួនថា វាកាប់គេ ខ្លួនក៏បានស្ដីឱ្យវាហើយវាក៏ចេញបាត់ ទៅ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ...ទៅផ្ទះរបស់ខ្លួនតែម្នាក់ឯង នៅម៉ោង១២យប់ នោះពុំមានកាំបិតទេ។ ខ្លួនបានឈរលេងនៅក្រោមដើមទឹកដោះគោចាប់ពីម៉ោង ៨យប់រហូតដល់ម៉ោង១០យប់ ដោយមានគ្នាបីនាក់មានឈ្មោះ...សំណូមពរ លើកលែងចោទប្រកាន់។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ ២៣ “ឃ” ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដី សម្រេចដូចតទៅ៖

**១ -** ផ្ដន្ទាទោស៖

ក- ឈ្មោះ...ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) តម្រូវឱ្យធ្វើការគិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

ខ- ឈ្មោះ...ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ

គ- ឈ្មោះ...ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ

ឃ- ឈ្មោះ...ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ តម្រូវឱ្យធ្វើការក្នុងម្នាក់ៗ កំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំគត់) គិតពីថ្ងៃចាប់ខ្លួន។

ពីបទៈមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ...ចំពោះមុខដើមបណ្តឹង។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ៤១ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ...ឧទ្ធរណ៍ និងសាលក្រមរបស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ០៤ ខែ១ ឆ្នាំ២០១០ របស់មហាអយ្យការសាលាឧទ្ធរណ៍

បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ លេខៈ០៩/១២ ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

បានឃើញដីកាព្រហ្មទណ្ឌលេខៈ ៣៨ "ញ" ចុះថ្ងៃទី ១៣ ខែ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៣ ខែ៣ ឆ្នាំ២០០៩ របស់ឈ្មោះ... ជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ២៣(ឃ) ចុះថ្ងៃទី ២៣ ខែ០២ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្ត បាត់ដំបង ទុកជាបានការដដែល។

៣- បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ...

៤- សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១៣.៨.២០១០ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹង។ ទុកសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់។

**នាពេលសវនាការ**

ឈ្មោះ...ឆ្លើយថា មុនកើតហេតុ ឈ្មោះ...បបួលខ្លួនទៅបត់ជើងធំ នៅទីនោះជាទីវាលមួយអ្នកណាក៏ទៅបត់ជើងនៅទីនោះ ហើយបបួលខ្លួនទៅមើលគេលេងធុងបាស់ លុះដើរចេញមកជួបឈ្មោះ...ហើយបានសួរសុខទុក្ខគ្នាជាធម្មតា រួចឈ្មោះ...បបួលខ្លួនទៅ ហើយមក ឈ្មោះ...ស្លាប់បានដើរទៅកន្លែងធុងបាស់ បន្ទាប់មកខ្លួនបានទៅដេកវិញ ក្រោយមកឈ្មោះ...ទៅគោះទ្វាសួររកពូវាឈ្មោះ...និងផ្ទះខ្លួនហើយ និយាយថា រកឃើញកាប់ឈ្មោះ...នោះ ខ្លួនបានលឺដូច្នេះ បានដេញវាឱ្យចេញ បន្ទាប់ខ្លួនបានដេកទល់ភ្លឺទៅ លុះព្រឹកឡើង គេហៅខ្លួនទៅបេអឹមក្រុងត្រូវគេចាប់ខ្លួនតែម្តង។ ខ្លួនមិនបានប្រព្រឹត្តទេ មុនកើតហេតុមិនបានជួបឈ្មោះ...មកផ្ទះនៅម៉ោង ១០ ទៅ ១០:៣០នាទី មានឈ្មោះ...មួយ

ដែលខ្លួនអង្គុយជិតនិយាយគ្នាបណ្តើរ។ នៅសាលាដំបូង ខ្លួនមានមេធាវីឈ្មោះ ...។ ជនរងគ្រោះខ្លួនស្គាល់មុខតែមិនស្គាល់ឈ្មោះ...ទេ គាត់អ្នកថាខ្លួនកាន់ដាវ សាំម៉ូរ៉ៃ ជនរងគ្រោះធ្លាប់ឃើញ។ ខ្លួននៅបាត់ដំបងជាងម្ភៃឆ្នាំ មិនដែលស្គាល់សាក្សីនេះទេ។ សព្វថ្ងៃជនដែលចាប់បាន គឺឈ្មោះ...ខ្លួនបានឃើញនៅពន្ធនាគារផ្ទាល់តែម្តង ជាប់នៅខេត្ត បាត់ដំបង មិនដឹងថាវាឆ្លើយយ៉ាងណាទេ។ សូមសំណូមពរសូមលើកលែងការចោទប្រកាន់ព្រោះខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់។

តំណាងមហាអយ្យការសន្និដ្ឋានថា ពាក់ព័ន្ធនឹងរឿងនេះ មានភាពស្មុគស្មាញច្រើន ចំណុចជនជាប់ចោទលើកឡើងពីសាក្សី យើងអាចទទួលយកបាន ប៉ុន្តែពុំមានចម្លើយ សូមឱ្យក្រុមប្រឹក្សាលើកទៅថ្ងៃក្រោយដើម្បីកោះហៅសាក្សីឈ្មោះ...សាកសួរនាពេលសវនាការពេលក្រោយ សូមឱ្យក្រុមប្រឹក្សាពិនិត្យពិចារណានិង សម្រេចតាមច្បាប់។

លោកមេធាវី...សន្និដ្ឋានការពារថា កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសសម្លាប់មនុស្សទេ សូមក្រុមប្រឹក្សាបង្អង់លើកទៅថ្ងៃក្រោយដើម្បីរកការពិត កុំឱ្យកូនក្តីខ្លួនជាប់ដោយអយុត្តិធម៌។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឆ្លើយ និងស្នើសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់ពិនិត្យឯកសារដែលពាក់ពន្ធ័ក្នុងសំណុំរឿង

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## សាលាឧទ្ធរណ៍-យល់ឃើញថា

១- បណ្ដឹងទាស់ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ...ទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ:៣៨ (ញ) ចុះថ្ងៃទី១៣ ខែ៨ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- នៅពេលសវនាការសាលាឧទ្ធរណ៍ ដើមបណ្ដឹងទាស់មិនយកភស្តុតាងថ្មីមកសាលាឧទ្ធរណ៍ ដើម្បីសាលាឧទ្ធរណ៍ ធ្វើការកែប្រែសេចក្ដីសម្រេចរបស់ខ្លួនឡើយ។

៣- តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា មានភាពស្មុគស្មាញច្រើន ហើយចំណុចជនជាប់ចោទលើកឡើងយើងទទួលយកបាន ប៉ុន្តែសាក្សីគាត់មិនមានចម្លើយ ហើយមេធាវីគាត់ មិនស្វែងរកមកដាក់ជូនតុលាការកន្លងមកជាក់ស្តែងឈ្មោះ...ចំណុចនេះមេធាវី មិនរកឱ្យដើម្បីដោះបន្ទុកឱ្យជនជាប់ចោទរូបនេះ ហើយសូមក្រុមប្រឹក្សាលើករឿងនេះទៅថ្ងៃក្រោយដើម្បីកោះហៅឈ្មោះ...សាកសួរនាពេលសវនាការពេលក្រោយ។ សាលាឧទ្ធរណ៍បានទុកពេលច្រើនមកហើយ គប្បីមិនលើករឿងនេះតទៅទៀតទេ។

៤-រឿងក្ដីនេះត្រូវបានសាលាឧទ្ធរណ៍ជំនុំជម្រះម្ដងមកហើយកាលពីថ្ងៃទី ១៣.៩.២០១០ តាមអំណាចសាលដីកាលេខ:៣៨(ញ) ហើយរហូតមកទល់ពេលនេះពុំមានភស្តុតាងណាបញ្ជាក់ថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាមិនបាននៅកន្លែងកើតហេតុ និងមិនបានប្រព្រឹត្តបទល្មើសមនុស្សឃាតដូចការអះអាងរបស់ជនជាប់ចោទឡើយ។

៥- សាលដីកាព្រហ្មទណ្ឌលេខៈ ៣៨(ញ) ចុះថ្ងៃទី ១៣ ខែ៨ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ ហើយ គប្បីតម្កល់ទុកជាបានការតទៅ។

## ហេតុដូច្នេះវិនិច្ឆ័យ

១- ទទួលបណ្ដឹងទាស់ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ... ត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខៈ ៣៨(ញ) ចុះថ្ងៃទី១៣ ខែ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

៣- សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១២ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។